**មាត្រា៤.–** ការចាត់តាំងគ្រូបង្រៀនអោយបំពេញភារកិច្ចបន្ថែម ឬ ភារកិច្ចថ្នាក់គួបត្រូវស្នើដោយនាយកសាលាបឋមសិក្សា ដោយមានការឯកភាពពីប្រធានការិយាល័យអប់រំ ស្រុក-ខណ្ឌ និងមានការយល់ព្រមពីប្រធានមន្ទីរអប់រំ យុវជន និងកីឡា ខេត្ត-ក្រុង ។

**មាត្រា៥.–** បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៦.–** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រី និង រដ្ឋលេខាធិការគ្រប់ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចកិច្ចរៀងៗខ្លួន ។

**មាត្រា៧.–** អនុក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៧

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

ហត្ថលេខា និង ត្រា

**អ៊ុង ហួត** **ហ៊ុន សែន**

* * *

**អនុក្រឹត្យលេខ ៧០ អនក្រ.បក**

**ស្តីពីការបង្កើតគណៈកម្មាធិការជាតិអូឡាំពិក**

**សំរាប់ជនពិការកម្ពុជា**

• • •

**រាជរដ្ឋាភិបាល**

–បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

–បានឃើញ ព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រ នៃព្រះរាជា- ណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា

–យោងតាមសំណើរបស់ អង្គការជនពិការកម្ពុជា

–ពិនិត្យសំណូមពរការងារ និង សមត្ថភាពរបស់មន្ត្រីរាជការ

## សំរេច

**មាត្រា១.**_បង្កើតគណៈកម្មាធិការជាតិអូឡាំពិកសំរាប់ជនពិការកម្ពុជា ដែលរួមមានសមាសភាព ÷

១_សម្តេច **ហ៊ុន សែន** នាយករដ្ឋមន្ត្រីទី ២ ជាប្រធាន

២_ឯកឧត្តម **ស៊ុយ សែម** រដ្ឋលេខាធិការក្រសួងសង្គមកិច្ចការងារ និងអតីតយុទ្ធជន ជាអនុប្រធាន

៣_ឯកឧត្តម **គា សាវាន** រដ្ឋលេខាធិការក្រសួងអប់រំយុវជន និងកីឡា ជាសមាជិក

៤_ឯកឧត្តម **ម៉ម ប៊ុនហេង** អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល ជាសមាជិក

៥_ឯកឧត្តម **ប៊ិន អ៊ុយ** អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ជាសមាជិក

៦_លោក **ប្រធានអង្គការជនពិការកម្ពុជា** ជាសមាជិក

**មាត្រា២.**_ គណៈកម្មាធិការជាតិអូឡាំពិក សំរាប់ជនពិការកម្ពុជា មានភារៈកិច្ចដឹកនាំការងារកីឡារបស់ជនពិការក្នុងក្របខណ្ឌជាតិ និងអន្តរជាតិ រៀបចំលេខាធិការដ្ឋាន និងសហព័ន្ធកីឡានានារបស់ជនពិការ ទំនាក់ទំនងរកការជួយឧបត្ថម្ភពីអន្តរជាតិ ដើម្បីបំរើអោយវិស័យកីឡារបស់ជនពិការ ។

**មាត្រា៣.**_សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ បណ្តាក្រសួងពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៧

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

ហត្ថលេខានិងត្រា

**អ៊ុង ហួត** **ហ៊ុន សែន**